**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៤...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៤១អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ .-**

មាត្រា៣ នៃអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា ត្រូវបានធ្វើការកែសម្រួលដូចតទៅៈ

**មាត្រា៣ .-ថ្មី**

ត្រូវបានបង្កើតក្រុមការងារស្រាវជ្រាវមួយសម្រាប់ជួយការងារក្រុមប្រឹក្សាយោធា ដែលមានសមាសភាពៈ

- រដ្ឋលេខាធិការក្រសួងការពារជាតិ ០១រូប ប្រធាន
- អនុរដ្ឋលេខាធិការក្រសួងការពារជាតិ មួយចំនួន សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងកងទ័ពជើងគោក ០១រូប សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងកងទ័ពជើងទឹក ០១រូប សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងកងទ័ពជើងអាកាស ០១រូប សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ០១រូប សមាជិក
- អគ្គលេខាធិការ ឬអគ្គលេខាធិការរងក្រសួងការពារជាតិ ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងអគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងអគ្គនាយកដ្ឋានយោធសេវា ០១រូប សមាជិក
- សាកលវិទ្យាធិការ ឬសាកលវិទ្យាធិការរងសាកលវិទ្យាល័យការពារជាតិ ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ០១រូប សមាជិក
- អគ្គនាយក ឬអគ្គនាយករងអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ០១រូប សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងគ្រប់យោធភូមិភាគ ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានស្ថាប័នអយ្យការយោធា ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានស្ថាប័នតុលាការយោធា ០១រូប សមាជិក
- នាយក ឬនាយករងនាយកដ្ឋានអធិការកិច្ច ០១រូប សមាជិក
- នាយក ឬនាយករងនាយកដ្ឋានបុគ្គលិក ០១រូប សមាជិក
- នាយក ឬនាយករងទីចាត់ការបុគ្គលិក ០១រូប សមាជិក
- នាយក ឬនាយករងទីចាត់ការហិរញ្ញវត្ថុ ០១រូប សមាជិក
- នាយក នាយកដ្ឋាននីតិកម្ម លេខាធិការ

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ